

Sâr Sarun

# សរសារុង

(១៩៣៨-១៩៧៧)

*ដោយ បណ្ឌិតសភាចារ្យ* **ឃីងហុកឌី**

*កើតនៅថ្ងៃ២០សីហា១៩៣៨ នៅភ្នំពេញ។ កុមារសរសារុនបានសិក្សានៅសាលាបឋមសិក្សានាក្រុងភ្នំពេញហើយបានចូលរៀននៅមធ្យមសិក្សាផ្នែកគរុវិជ្ជា* (Section de l´école normale) *បួនឆ្នាំក្រោយលោកឡុចផ្ទៃង។ តែយុវជនសរសារុនបានប្រឡងចូលរៀននៅវិទ្យាស្ថានគរុកោសល្យ ជំនាន់ទី២ គឺនៅឆ្នាំសិក្សា១៩៦០-៦១ជាមួយជំនាន់លោកឡុច-ផ្ទៃង, ឡុង-សៀម, គាម-ទត ជាដើម។*[1] *ក្រោយមកលោកសរសារុនបានទទួល*

[1] *តាមពត៌មានពីលោកគ្រូឡុចផ្ទៃង (កើត១៩៣២) អតីតសាស្ត្រាចារ្យអក្សរសិល្ប៍និងអតីតប្រធានខេមរយានកម្មនៅកម្ពុជា។*

តំណែងជាសាស្ត្រាចារ្យមធ្យមសិក្សាបឋមភូមិបង្រៀនរវាងឆ្នាំ ១៩៦២-៦៣ហើយបានបង្រៀននៅអនុវិទ្យាល័យព្រះនរោត្តម ក្រុងភ្នំពេញ។[2]បន្ទាប់ពីលោកបានប្រឡងជាប់ បរិញ្ញាប័ត្រភាសា និងអក្សរសាស្ត្រខ្មែររវាងឆ្នាំ១៩៦៧[3]មក លោកបានទទួល

[2] « ខ្ញុំមិនសូវដឹងរឿងរ៉ាវជីវិតគាត់ទេ គ្រាន់តែដឹងថា គាត់ជាសាស្ត្រាចារ្យរបស់ខ្ញុំផ្នែកអក្សរសាស្ត្រខ្មែរកាលពីឆ្នាំ១៩៦៣-៦៤នៅអនុវិទ្យាល័យនារីព្រះនរោត្តម។ រំលឹកអនុស្សាវរីយ៍ខ្លះៗ កាលពីគាត់ធ្វើអត្ថាធិប្បាយរឿងទុំទាវត្រង់នាងទាវឃើញនេនទុំចូលមកស្ងួតនៅផ្ទះនាង មានឃ្លាមួយថា‹‹អើតអើមដកកប្រហមាត់ ចង់ចេញប្រាកដគ្មានគេហៅ...›› ។ពេលនោះពួកសិស្សដែលសុទ្ធតែជាស្រីៗបាននាំគ្នាស្រែកហ៊ោផងគោះតុផង ធ្វើឱ្យគាត់អៀនយ៉ាងខ្លាំង មុខឡើងក្រហម ដោយកាលនោះគាត់នៅលីវនៅឡើយ។តាមដឹងខ្លះៗថាកាលនោះគាត់មានចំណងស្នេហ៍ជាមួយនារីម្នាក់រួចទៅហើយ។ បន្ទាប់ពីខ្ញុំប្រឡងជាប់ឌីប្លូមមកខ្ញុំក៏ផ្លាស់ទៅរៀននៅ Lycée Sisowath បាត់ ក៏ដាច់ដំណឹងគាត់ទៅ។ កន្លងមក នៅឆ្នាំ១៩៧១ខ្ញុំក៏បានចូលរៀននៅ Université Phnom Penh ។ពេលនោះខ្ញុំបានក្លាយជាសិស្សគាត់ម្តងទៀត គឺគាត់បានបង្រៀនអក្សរសាស្ត្រខ្មែរផ្នែកទស្សនវិជ្ជា។ » នេះជាចំណាប់អារម្មណ៍អតីតសិស្សនារីចាស់ម្នាក់របស់លោកគ្រូសរសារុន នៅអនុវិទ្យាល័យព្រះនរោត្តម ឈ្មោះអ្នកស្រីនាង-អេងជាអតីតគ្រូបង្រៀន ដែលរស់នៅរហូតដល់សព្វថ្ងៃនៅប្រទេស កាណាដា។

[3] នៅឆ្នាំ១៩៦៣ មានតែម្នាក់ទេដែលបានប្រឡងជាប់បរិញ្ញាប័ត្រអក្សរសាស្ត្រគឺលោក **តែមេង៉ហាប់**។ នៅឆ្នាំ១៩៦៤ មានពីរនាក់បានទទួលបរិញ្ញាប័ត្រអក្សរសាស្ត្រ គឺ លោក **ខ្វាន់ស៊ីផាន** និង កញ្ញា**ង៉ួនប៊ូផារី** ហើយឆ្នាំ១៩៦៥ មានប្រាំនាក់បានទទួលបរិញ្ញាប័ត្រ គឺលោក **ដ៉ោថុនលាក់** បរិញ្ញាប័ត្រអក្សរសាស្ត្រ, លោក **ចន្ទនិត្យ** បរិញ្ញាប័ត្រប្រវត្តិសាស្ត្រ វប្បធម៌និងអរិយធម៌, លោក **ម៉ាក់**

*តំណែងជាសាស្ត្រាចារ្យ មធ្យមសិក្សាទុតិយភូមិឯកទេសអក្សរសាស្ត្រ និងវប្បធម៌អរិយធម៌ខ្មែរហើយលោកបានទទួល ការតែងតាំងជានាយក មធ្យមសិក្សា ប្រចាំខែត្រព្រៃវែងទាំងមូល មួយរយៈពេល។*[4]

*លោកបានចូលជាសមាជិកសង្គមរាស្ត្រនិយមនៅថ្ងៃ១០ មករា១៩៦១កាន់អត្តសញ្ញាប័ណ្ណ លេខ២២៣ ដូចមានរូបថតខាងក្រោមបញ្ជាក់ស្រាប់។*

**ភឹង** *បរិញ្ញាប័ត្រប្រវត្តិសាស្ត្រ វប្បធម៌និងអរិយធម៌ លោក***ត្រឹងង៉ា** *បរិញ្ញាប័ត្រប្រវត្តិសាស្ត្រ វប្បធម៌និងអរិយធម៌ និង លោក***ព្រុំម៉ល់** *បរិញ្ញាប័ត្រអក្សរសាស្ត្របារាំង។ សូមអាន* CHAU Seng, *Les élites khmères*, Phnom Penh, Université Bouddhique Preah Sihanouk Raj, 1965, p. 158។

4 *ពត៌មានបានមកពីលោកគ្រូឡុចផ្ទៃង។*


# សាស្ត្រាចារ្យ សរ សារុន

Sah. SAR SARUN

né le 20 août 1938 à Phnom-Penh

- membre du Sangkum, carte nº 223 du 10 janvier 1961.
- licencié es-lettres de l'Université Royale.
- professeur à la Faculté des Lettres et des Sciences Humai[nes]
Collège Preah Norodom

*អត្តសញ្ញាប័ណ្ណសម្គាល់សមាជិកសង្គមរាស្ត្រនិយមចុះផ្សាយក្នុងទស្សនាវដ្ដី ឡឺសង្គម(Le Sangkum)*

តាមរយៈលោកសាស្ត្រាចារ្យ កេងវ៉ាន់សាក់ ចាប់ពីឆ្នាំ ១៩៦៨ លោកសរ សារុន បានទទួលតំណែងជាសាស្ត្រាចារ្យជំនួយនៅមហាវិទ្យាល័យអក្សរសាស្ត្រ និងមនុស្សសាស្ត្រក្រុងភ្នំពេញ បង្រៀន ថ្នាក់ត្រៀម Propédeutique ជំនួស សាស្ត្រាចារ្យ

*ធុចរិន ឈប់ធ្វើការហើយបានរត់ចូលព្រៃជាមួយពួកកម្មុយនីស្ត ខ្មែរក្រហម។[5] តាមពត៌មាននិងកំណត់ត្រាស្រង់ដោយអ៊ុចភិរម្យ ដឹងថាលោកស្លាប់រវាងឆ្នាំ១៩៧៧ដូចមានសេចក្តីបញ្ជាក់ខាង ក្រោមនេះ៖*

« *លោក សោម សួនធ្លាប់រស់នៅជាមួយលោកគ្រូ (សរសារុន)ជំនាន់ប៉ុលពត ហើយលោកបានពោលប្រាប់ថា៖ សាស្ត្រាចារ្យសរសារុនបាត់ខ្លួនឆ្នាំ១៩៧៧*...! *ព្រោះលោកគ្រូ សរសារុនបានធ្លាប់រស់នៅក្នុងជំនាន់ប៉ុលពតពីឆ្នាំ១៩៧៥ទៅ១៩៧៧ ជាមួយគ្នានឹងគាត់គឺនៅក្នុង ឃុំថ្លាមអំពិល ស្រុកកណ្ដៀត ខេត្តពោធិសាត់។*»

*ស្នាដៃបោះពុម្ពផ្សាយ៖*

-*វប្បធម៌និងអរិយធម៌ ភាគទី១* + *និង ភាគទី២*, *ភ្នំពេញ*, *បណ្ណាគារពន្លឺវិទ្យា*, *១៩៧០*,*២២៦ទំព័រ*។[6]

---

[5] *តាមប្រភពពីលោកអ៊ុចភិរម្យថា នៅថ្នាក់ត្រៀម* propédeutique *មហាវិទ្យាល័យអក្សរសាស្ត្រ បន្ទប់* amphitheâtre *កូនសិស្ស ផ្នែកផ្សេងក៏ចូលចិត្តទៅស្តាប់លោកគ្រូ* (*សរសារុន*)*ដែរ*...*ជំនាន់នោះរដ្ឋាភិបាលមិនសូវចូលចិត្តលោកគ្រូ នួន ឃឿន លោកគ្រូ សរសារុនទេ*....!)

[6] *សូមប្រៀបធៀបស្នាដៃលោកគ្រូសរសារុន នេះ នឹងស្នាដៃ អ្នកស្រី ត្រឹងងា*, *អរិយធម៌ខ្មែរ*, *ថ្នាក់បញ្ចប់*, *ភ្នំពេញ*, *២៣៨ ទំព័រ* (*បោះពុម្ពលើកទី៣នាឆ្នាំ១៩៧៤*)។ *សៀវភៅលោកគ្រូសរសារុន និង សៀវភៅ អ្នកគ្រូ ត្រឹងងា មានទម្រង់ដូចគ្នាដោយអន្ទើ ព្រោះបានចេញពីពុម្ពមួយ គឺពីមេរៀនលោកសាស្ត្រាចារ្យ កេងវ៉ាន់សាក់រវាងឆ្នាំ១៩៦៤ដល់១៩៦៧។ល។ អ្នកទាំងពីរនេះជានិស្សិត*

-ល្បងសិក្សាសង្គមវិជ្ជាខ្មែរ La sociologie khmère, ភ្នំពេញ, ១៩៧៣-៧៤, ១៦៧ទំព័រ។

-អត្ថាធិប្បាយ ទស្សនវិជ្ជា La dissertation philosophique, ភ្នំពេញ, ១៩៧៤។

កម្មវិធីសម្រាប់និស្សិតរៀនយកវិញ្ញាបនប័ត្រ ឧត្តមសិក្សាអក្សរសិល្ប៍ខ្មែរ (CES Littérature khmère) នៅមហាវិទ្យាល័យអក្សរសាស្ត្រនិងមនុស្សសាស្ត្រក្រុងភ្នំពេញនាឆ្នាំសិក្សា១៩៧០-៧១ដោយសាស្ត្រាចារ្យសរសារុន, សាស្ត្រាចារ្យឡុចផ្ទៃង, សាស្ត្រាចារ្យអ៊ុំងគិមអេង និង សាស្ត្រាចារ្យលីគីមឡុង៖

---

ចាស់សាស្ត្រាចារ្យ គេងរ៉ាន់សាក់ក្នុងជំនាន់ជាមួយគ្នានៅមហាវិទ្យាល័យអក្សរសាស្ត្រនិងមនុស្សសាស្ត្រ។

PROGRAMMES :

1°- Programme de Littérature khmère

par M.SAR SARUN (4h. hebdomadaires)

Textes d'influence hindoue et textes khmers.

A- Objet de la Littérature

-Sens large et sens restreint de la Littérature khmère

-La Littérature khmère telle que nous concevons aujourd'hui

-Le parallélisme entre la littérature khmère et la littérature étrangère

-Source de la Littérature khmère

-Genres littéraires

a/-
1°- Poeme
2°- Prose
3°- Poème en prose

b/-
1°- Roman
2°- Pièce de théâtre
3°- Contes et légendes
4°- Genre didactique
5°- Jâtaka
6°- Essai et Etude
7°- Genre épistolaire
8°- Genre épique
9°- Genre à thèse
10°- Commentaire
11°- Genre romantique à des fins philosophiques
12°- Histoire de la littérature khmère

- Critère de la littérature khmère fixé par un comité d'élaboration du programme
- Caractère de la littérature khmère
- Particularités de la littérature khmère
- Thème littéraire : études du fond, de la forme et de la valeur du texte .

B- Méthodes et Procédés de la Littérature :
- Méthodes simples
- Méthodes scientifiques
- Méthodes philosophiques

C- Théories littéraires :
- Le Réel
- Le Merveilleux
- La Synthèse du Réel et du Merveilleux

2º Programme de Littérature khmère
par M. LOCH PHLENG (2h hebdomadaires)

ក - អក្សរសិល្ប៍ទូទៅ :

- ន័យអក្សរសិល្ប៍
- វត្ថុអក្សរសិល្ប៍
- មូលដ្ឋានអក្សរសិល្ប៍
- បំណងអក្សរសិល្ប៍
- លក្ខណៈអក្សរសិល្ប៍
- ប្រវត្តិអក្សរសិល្ប៍
- សភាពអក្សរសិល្ប៍
- អត្ថបទអក្សរសិល្ប៍
- ប្រភេទអក្សរសិល្ប៍
- អ្នកអក្សរសិល្ប៍
- ចលនាអក្សរសិល្ប៍
- បញ្ហាអក្សរសិល្ប៍
- ទ្រឹស្ដីអក្សរសិល្ប៍
- វិធីអក្សរសិល្ប៍
- រសអក្សរសិល្ប៍

ខ - អក្សរសិល្ប៍ពិសេស :

១ - រឿងព្រេង
២ - រឿងល្បើក
៣ - រឿងជាតក
៤ - រឿងប្រលោមលោក
៥ - រឿងល្ខោន :
- ន័យ
- បំណងរឿង
- ចំនួន
- អ្នកនិពន្ធ
- កាលកំណត់
- ប្រភព
- សភាព
- ប្រភេទ
- ចលនា
- តួ
- ទឹកភ្លេង
- ពេលវេលា
- បញ្ហា
- អត្ថរូប
- អត្ថរស
- តម្លៃ

3º ការសិក្សាអក្សរសិល្ប៍ខ្មែរផ្នែកពុទ្ធនិយមដោយលោក អ៊ឹង គិម អេង ( ២ ម៉ោងក្នុង ១ សប្ដាហ៍ )

ក - ផ្នែកទ្រឹស្ដី :
- និយមន័យទូទៅនៃពាក្យអក្សរសិល្ប៍ខ្មែរ
- និយមន័យនៃពាក្យអក្សរសិល្ប៍ខ្មែរផ្នែកពុទ្ធនិយម
- ពុទ្ធប្រវត្តិសង្ខេប
- ពុទ្ធសាសនា និងពុទ្ធនិយម
- អក្សរសិល្ប៍ពុទ្ធនិយម និងអក្សរសិល្ប៍ខ្មែរពុទ្ធនិយម
- ពោធិសត្វក្នុងថេរវាទ និងពោធិសត្វក្នុងមហាយាន
- លក្ខណៈពិសេសនៃពោធិសត្វ និងលក្ខណៈសាទិទេព
- ទសបារមី និងទសពល និងទសពិធរាជធម៌
- ពុទ្ធលទ្ធិសង្ខេបអំពីកម្មផល អំពីអនត្តា អំពីអរិយសច្ច

ខ- ផ្នែកអនុវត្តន៍ :

- តែងសេចក្ដីដោយលើកយកប្រធានបទផ្សេងៗដែលមានចោទនិងដោះស្រាយនៅក្នុងអក្សរសិល្ប៍ខ្មែរពុទ្ធនិយម
- ពន្យល់អត្ថបទដោយសំអាងទៅលើទសជាតកនិងបញ្ញាសជាតក

4°- Programme d'ESTHETIQUE DANS LA LITTERATURE KHMERE
par M. LY KIM LONG (2h hebdomadaires )

ក- សិល្បវិជ្ជាទូទៅ :

១- វត្ថុនៃសិល្បវិជ្ជា
២- វិធីនៃសិល្បវិជ្ជា
៣- ទ្រឹស្ដីសិល្បវិជ្ជា : - តាមទស្សនវិទូអឺរ៉ុប
- តាមទស្សនវិទូឥណ្ឌា

ខ- សិល្បវិជ្ជាក្នុងអក្សរសិល្ប៍ខ្មែរ :

១- សិល្បរសក្នុងរឿងទុំទាវ
២- សិល្បរសក្នុងរឿងកាកី
៣- សិល្បរសក្នុងបណ្ដាំក្រមង៉ុយ

គ- កិច្ចការហ្វឹកហាត់ :

ការហាត់និងសាកល្បងធ្វើអត្ថាធិប្បាយលើរឿងណាមួយ ឬ អត្ថបទណាមួយ

B I B L I O G R A P H I E :

1°-Bibliographie par M. SAR SARUN

- រាមកេរ្ដិ៍ខ្មែរ
- រាមាយណៈ - អធ្យាត្មរាមាយណៈ - រាមចរិតមានស
- រឿងទុំទាវ - ភោគកុលកុមារ
- ច្បាប់ផ្សេងៗ
- ទិដ្ឋភាពខ្លះនៃអក្សរសិល្ប៍ខ្មែរ របស់លោក កេង វ៉ាន់សាក់
- អក្សរសិល្ប៍ខ្មែរ វិធីសាស្រ្តពន្យល់ របស់លោក លាង ហាប់ អាន
- អត្ថាធិប្បាយរាមកេរ្ដិ៍ ខ្មែរ របស់លោក លាង ហាប់ អាន
- វប្បធម៌ អរិយធម៌ ខ្មែរសិក្សាបែបទស្សនវិជ្ជា របស់លោក សរ សារុន

2°- Bibliographie par M. LOCH PHLENG

- សៀវភៅប្រជុំរឿងព្រេងខ្មែរ
- សៀវភៅរឿងល្បើកខ្មែរ
- សៀវភៅគតិលោក
- សៀវភៅប្រលោមលោកខ្មែរ
- សៀវភៅរឿងល្ខោនខ្មែរ
- សៀវភៅរឿងជាតកខ្មែរ

*កម្មវិធីនេះស្រង់ចេញពីកំរងព័ត៌មាននៃមហាវិទ្យាល័យ*

*អក្សរសាស្ត្រ&មនុស្សសាស្ត្រ ភ្នំពេញ ឆ្នាំសិក្សាឆ្នាំ១៩៧០ -៧១*



សាធារណរដ្ឋខ្មែរ
អំរខពតិមាន
នៃ មហាវិទ្យាល័យ អក្សរសាស្ត្រ & មនុស្សសាស្ត្រ ភ្នំពេញ
ឆ្នាំសិក្សា ១៩៧០–៧១
ANNUAIRE
DE LA FACULTÉ DES LETTRES
ET DES SCIENCES HUMAINES DE PHNOM - PENH
ANNEE UNIVERSITAIRE 1970-71
REPUBLIQUE KHMERE

# ឧបសម្ព័ន្ធ



Ph.Loch Phléng

*រូបថត គរុសិស្ស ជំនាន់ទី២ នៅវិទ្យាស្ថានជាតិគរុកោសល្យ ភ្នំពេញ ១៩៦០-១៩៦១។ នៅជួរទី១ សាស្ត្រាចារ្យកេងវ៉ាន់សាក់នាយកវិទ្យាស្ថានគរុកោសល្យ អង្គុយទី១០ពីឆ្វេងទៅស្តាំនៅជិតភរិយាលោកអ្នកស្រី ស៊ុយស្ហាន ស្លៀកសំពត់ផ្កា នៅជិត* Claude Biessy *ពាក់វ៉ែនតាស្លៀកខោអាវពណ៌ស ហើយនៅជិតលោកម្នាក់ទៀតគឺ លោកសុនសេន ជានាយករង វិទ្យាស្ថាននេះ។*

*(រូបថត របស់សាស្ត្រាចារ្យ ឡុចផ្លេង, ១៩៦០).*

*លោកឡុងសៀមឈរក្រោយបង្អស់ ទី៤ពីឆ្វេងទៅស្តាំ*

*លោកឡុចផ្លេងឈរក្រោយបង្អស់ ទី១២ពីឆ្វេងទៅស្តាំ។*

*លោកសរសារុន ឈរនៅក្នុងចំណោមមិត្តរួមជំនាន់ទី២*

*នៃវិទ្យាស្ថានគរុកោសោល្យ។*




វប្បធម៌និងអរិយធម៌ ភាគទី១ + និង ភាគទី២, ភ្នំពេញ, បណ្ណាគារពន្លឺវិទ្យា, ១៩៧០,២២៦ទំព័រ។




*ល្បងសិក្សាសង្គមវិជ្ជាខ្មែរ* La sociologie khmère,

*ភ្នំពេញ*, ១៩៧៣-៧៤, ១៦៧ទំព័រ។




អត្ថាធិប្បាយ ទស្សនវិជ្ជា La dissertation philosophique,

ភ្នំពេញ, ១៩៧៤។




*រូបថតនេះលោក អ៊ុចតិរម្យ បានស្រង់ចេញពីទស្សនាវដ្ដី* Le Sangkum
*(សូមអរគុណលោកដោយបានចែករំលែករូបថតនេះ)។*